ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ការវាយតម្លៃផលជះនៃការអនុវត្ត "កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា" និង "កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់"

# Impact Evaluation of the Cash Transfer Programmes for At-Risk Households Affected by Inflationary Pressure and Severe Floods

## សង្ខេបគោលនយោបាយ៖ លេខ ៩

សង្ខេបគោលនយោបាយនេះផ្តល់លទ្ធផលសង្ខេបគន្លឹះនៃការវាយតម្លៃផលជះនៃការអនុវត្ត “កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា” និង “កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់”។

## POLICY BRIEF VOL. 9

This policy brief summarizes the impact evaluation results of the Royal Government of Cambodia’s cash transfer programmes for at-risk households affected by inflationary pressure and severe floods.




រូបភាព៖ GS-NSPC

កុម្ភៈ ២០២៤ - FEB 2024

## ១. សារបាន

ក្នុងឆ្នាំ២០២២ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ពិសេសចំនួន ២ រួមមាន "កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា" និង "កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់" ដោយផ្អែកលើគោលការណ៍នៃការអនុវត្តប្រព័ន្ធគាំពារសង្គមប្រកបដោយភាពបត់បែន និងឆ្លើយតបនឹងគ្រោះអាសន្ន, ក្នុងគោលបំណងជួយទ្រទ្រង់ជីវភាពគ្រួសារងាយរងហានិភ័យដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ និងងាយធ្លាក់ចូលក្នុងភាពក្រីក្រ នៅពេលមានគ្រោះអាសន្ននានា។

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ទាំងពីរនេះ ត្រូវបានអនុវត្តចាប់ពីខែធ្នូ ឆ្នាំ-២០២២ ដល់ខែកក្កដា ឆ្នាំ២០២៣ ដោយគ្របដណ្តប់គ្រួសារគោលដៅចំនួន ៤៩៥ ៣០៧ គ្រួសារ ស្មើនឹង ១ ៨៣៣ ៣៤៤ នាក់ នៅទូទាំងប្រទេស រួមទាំងតំបន់ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ក្នុងរាជធានី-ខេត្តចំនួន ១៦។ រាជរដ្ឋាភិបាលបានចំណាយថវិកាជាតិសរុបចំនួន ២២២ ប៊ីលានរៀល ឬស្មើនឹងប្រមាណ ៥៥,៧ លានដុល្លារអាមេរិកសម្រាប់អនុវត្តកម្មវិធីទាំង ២ នេះ។

## I. BACKGROUND

In 2022, the Royal Government of Cambodia (RGC) launched two cash transfer programmes to support the livelihoods of At-Risk Households affected by inflationary pressure and severe floods. The programmes were introduced under the principle of adaptive and shock responsive social protection. At-risk households are identified as near poor households that are likely to fall into poverty from disruptions and economic shocks in times of crisis.

The programmes were implemented between December 2022 and July 2023 and benefitted 495,307 households – equivalent to 1,833,344 people. The inflation cash transfer programme offered nationwide coverage, while the severe flood cash transfer programme covered affected areas in 16 capital/provinces. In total, the government spent more than Riel (KHR) 222 billion, equivalent to US$55.7 million on the two programmes.

### ប្រអប់ទី១ ៖ ឯកសារគតិយុត្ត

១. សេចក្តីសម្រេចរាជរដ្ឋាភិបាលលេខ៦៧ សសរ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២២ ស្តីពីអន្តរាគមន៍គាំពារសង្គមដើម្បីឆ្លើយតបនឹងសម្ពាធអតិផរណា។

២. សេចក្តីសម្រេចលេខ១៣៤/សហវ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២ ស្តីពីយន្តការ និងនីតិវិធី នៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា។

៣. សេចក្តីសម្រេចលេខ១៣៣/សហវ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២ ស្តីពីយន្តការ និងនីតិវិធី នៃការអនុវត្តកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់។

### Box 1: Regulatory documents

1) Royal Government of Cambodia's Decision No. 67 SSR dated 5 October 2022 on Social Protection Intervention Responding to Inflationary Pressure

2) National Social Protection Council's Decision No. 134/MEF dated 1 December 2022 on Mechanism and Procedure for the Implementation of the Cash Transfer Programme for At-Risk Households during Inflationary Pressure

3) National Social Protection Council's Decision No. 133/MEF dated 1 December 2022 on Mechanism and Procedure for the Implementation of the Cash Transfer Programme for At-Risk Households Affected by Severe Flood

### ប្រអប់ទី២ ៖ និយមន័យគ្រួសារងាយរងហានិភ័យ

គ្រួសារងាយរងហានិភ័យ សំដៅដល់គ្រួសារដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ និងមានសមាជិកគ្រួសារមានភាពងាយរងគ្រោះ ១ ក្នុងចំណោម ៥ ដូចជា៖ ជនមានពិការភាព, កុមារអាយុក្រោម២ឆ្នាំ, ជនចាស់ជរាអាយុចាប់ពី៦០ឆ្នាំឡើង, ស្ត្រីជាមេគ្រួសារ និងរស់នៅដោយគ្មានស្វាមី, ឬគ្រួសារ ដែលមានសមាជិកសុទ្ធសឹងជាកុមារ និងមនុស្សចាស់ជរា ដែលត្រូវបានកំណត់អត្តសញ្ញាណដោយក្រសួងផែនការ តាមរយៈយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

### គោលបំណង និងវិធីសាស្ត្រនៃការវាយតម្លៃ

ការវាយតម្លៃផលជះនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ទាំង ២ នេះ មានគោលបំណងពិនិត្យលើលទ្ធផលនៃការអនុវត្តកម្មវិធីទាំងនេះ និងឥទ្ធិពលផ្នែកសង្គម-សេដ្ឋកិច្ច លើស្ថានភាពគ្រួសារងាយរងហានិភ័យ ដើម្បីរៀបចំជាភស្តុតាងសម្រាប់រៀបចំ និងអនុវត្តអន្តរាគមន៍គាំពារសង្គមនានាឱ្យកាន់តែល្អប្រសើរ នាពេលអនាគត។ ការវាយតម្លៃនេះបានប្រើប្រាស់វិធីសាស្ត្របរិមាណវិស័យ (Quantitative) និងគុណវិស័យ (Qualitative) ដោយធ្វើការប្រមូលទិន្នន័យចំនួន ២ លើក៖ លើកទី១ ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ និងលើកទី២ ក្នុងខែសីហា ឆ្នាំ២០២៣ ជាមួយសំណាកសរុបចំនួន ៨១១ គ្រួសារ ក្នុងនោះគ្រួសារទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធី (គ្រួសារគោលដៅ) ចំនួន ៤១៥ និងគ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភ (Control group) ចំនួន ៣៩៦។ វិធីសាស្ត្រ Propensity Score Matching និង Difference-in-difference (DID) ត្រូវបានប្រើប្រាស់សម្រាប់ការវិភាគបរិមាណវិស័យ រួមជាមួយការសម្ភាសន៍ស៊ីជម្រៅលើគ្រួសារគោលដៅផងដែរ ។

## ២. លទ្ធផលនៃការវាយតម្លៃ

ជារួម, គ្រួសារគោលដៅ (ប្រមាណ៩៧%) យល់ឃើញថាការគាំទ្ររបស់រាជរដ្ឋាភិបាលក្នុងទម្រង់ជាសាច់ប្រាក់ឧបត្ថម្ភនេះ មានភាពចាំបាច់ និងមានអត្ថប្រយោជន៍ខ្ពស់ បើប្រៀបធៀបទៅនឹងទម្រង់ការគាំទ្រដទៃទៀត។ ក្នុងអំឡុងពេលកម្មវិធី, គ្រួសារគោលដៅបានប្រើប្រាស់សាច់ប្រាក់ឧបត្ថម្ភ សម្រាប់ចំណាយលើម្ហូបអាហារ (៩៤% នៃគ្រួសារគោលដៅសរុប), សេវាសុខាភិបាល និងឱសថ (៥០%), ការសិក្សារបស់កូន (២០%), ការចូលរួមបុណ្យទាន និងមង្គលការ

### Box 2: Definition of at-risk households

At-risk households refer to near poor households that meet at least one of the following five vulnerabilities: include a person with disabilities; include a child under two years old; include an elderly person 60 years old and above; are single women-headed; or consist only of members under 18 years old. The househoulds are identified through the Ministry of Planning's IDPoor mechanism.

### Objective and Methodology

The objective of the conducted impact evaluation was to examine the key socioeconomic outcomes and impacts of the cash transfer programmes for at-risk households in order to inform future interventions. The impact evaluation included both quantitative and qualitative methods. Quantitative surveys were administered in two intervals, in February 2023 and August 2023. Surveys were conducted with a total sample of 811 that was roughly equal in size (415 recipients, 396 non-recipients), and a two-step framework was employed. First, Propensity Score Matching (PSM) with single nearest neighbor matching without replacement was used in each round. Second, the matched samples in each round were used to estimate the impact between the two rounds of interviews using Difference-in-Difference Analysis (DID). Case studies through in-depth interviews were also conducted to complement the quantitative surveys.

## II. IMPACT EVALUATION RESULTS

Overall, recipient households viewed support in the form of cash transfers as highly useful (97 percent) compared to other forms of support. As anticipated, for the duration of the programmes, the purchase of food was the most common use for the cash transfers among households and was reported by 94 percent of those surveyed. This was followed by expenditure on medicine (50 percent), education (20 percent),

(១៥%), ការប្រើប្រាស់សេវាទឹក-ភ្លើង (៩%), និងការទូទាត់បំណុល (៦%)។ និន្នាការចំណាយខាងលើបានបង្ហាញថាគ្រួសារគោលដៅបានចំណាយមួយផ្នែកធំនៃសាច់ប្រាក់ដែលទទួលបានលើមុខចំណាយចាំបាច់ដូចជាម្ហូបអាហារ, សេវាសុខាភិបាល និងឱសថ ,និងការសិក្សារបស់កូន ដូចមានក្នុងរូបភាពទី១។

ceremonies (e.g., weddings, death anniversaries, and religious events) (15 percent), utilities (9 percent), and debt payments (6 percent). The general trend indicates that the larger share of cash transfer expenditure was on food, medicine, and education (see Figure 1).

**រូបភាពទី១៖ ការប្រើប្រាស់សាច់ប្រាក់ឧបត្ថម្ភ**




**Figure 1: Cash transfer expenditures**



## លទ្ធផលនៃសូចនាករសង្គម-សេដ្ឋកិច្ចគន្លឹះ

### សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ផ្អែកលើការវិភាគដោយប្រើប្រាស់វិធីសាស្ត្រ Food Insecurity Experience Scale (FIES) , ស្ថានភាពសន្តិសុខស្បៀងរបស់គ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភមានភាពល្អប្រសើរជាងគ្រួសារគោលដៅនៃកម្មវិធី មុនពេលកម្មវិធីត្រូវបានដាក់ឱ្យអនុវត្ត។ ផ្ទុយទៅវិញ ការវាយតម្លៃបានបង្ហាញថាស្ថានភាពសន្តិសុខស្បៀងក្នុងគ្រួសាររបស់ក្រុមទាំងពីរមានភាពប្រហាក់ប្រហែលគ្នា បន្ទាប់ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ត្រូវបានបិទបញ្ចប់ក្នុងខែកក្កដា ឆ្នាំ២០២៣ ដូចមានក្នុងរូបភាពទី២។ តាមការវិភាគ ស្ថានភាពសន្តិសុខស្បៀងរបស់គ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភមានការធ្លាក់ចុះ មកត្រឹមកម្រិតទាបជាងគ្រួសារគោលដៅ ដោយក្នុងនោះសាច់ប្រាក់ឧបត្ថម្ភបានទប់ស្កាត់ការកើនឡើងនៃអត្រាអសន្តិសុខស្បៀងរបស់គ្រួសារគោលដៅចំនួន ១៣%។

**រូបភាពទី២៖ អត្រាសន្តិសុខស្បៀងក្នុងគ្រួសារ**




*អ្នកទទួលផល "ក" ៖ "មុនពេលទទួលបានសាច់ប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល, គ្រួសាររបស់ខ្ញុំមានជីវភាពលំបាកជាខ្លាំង។ គ្រួសាររបស់ខ្ញុំពុំមានមុខរបរ និងប្រាក់ចំណូលទៀងទាត់។ គ្រួសាររបស់ខ្ញុំរកចំណូលបាន ៥ ០០០ ទៅ ១០ ០០០ រៀល ក្នុងមួយថ្ងៃ តាមរយៈការបេះស្លឹកកណ្ដៀងលក់ សម្រាប់ទិញម្ហូបអាហារ។ ពេលខ្លះ គ្រួសាររបស់ខ្ញុំមិនមានប្រាក់ទិញម្ហូបអាហារទេ និងត្រូវខ្ចីប្រាក់គេ។"*

## Key socioeconomic results

### Food security and nutrition

Based on the Food Insecurity Experience Scale (FIES), food security was significantly greater among non-recipient households before the cash transfer compared to recipient households. However, by the end of the cash transfer programme in July 2023, a reassessment of food security showed an insignificant difference between recipients and non-recipients, as shown in Figure 2. In comparison, the non-recipient were slightly more food insecure than the recipients, and it is illustrated that the cash transfers prevented food security among the recipients from fallen by 13%, suggesting that the cash transfer was responsible for protecting recipient households from a significant decline in food security.

**Figure 2: Estimated impact on household food security by survey round**




*Recipient A - "Before receiving the support allowance, my family went through a very difficult condition because we had no business, no income, only picking [Kandieng] leaves to sell. We were earning only 5,000 to 10,000 KHR per day. I used it to buy rice and other food items daily. Sometimes I didn't have money at all, and I used to borrow to have rice to eat."*

## ការចំណាយសេវាសុខាភិបាល និងសេវាទឹក-ភ្លើង និងជួលផ្ទះ

ការវិភាគបានបង្ហាញថា លទ្ធភាពរបស់គ្រួសារគោលដៅ និងគ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភក្នុងការចំណាយចាំបាច់នានា មានភាពខុសគ្នានៅពេលកម្មវិធីឧបត្ថម្ភសាច់ប្រាក់ត្រូវបានបិទបញ្ចប់។ គ្រួសារគោលដៅមានលទ្ធភាពខ្ពស់ជាងគ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភក្នុងការចំណាយលើសេវាសុខាភិបាល និងឱសថដូចមានក្នុងរូបភាពទី៣។ គ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភចំនួន ៦១% បានរាយការណ៍ថា ធ្លាប់មិនមានលទ្ធភាពបង់ថ្លៃសេវាសុខាភិបាល និងឱសថ ខណៈដែរគ្រួសារគោលដៅចំនួន ៣៤% តែប៉ុណ្ណោះ ធ្លាប់បានជួបប្រទះបញ្ហានេះ។ សម្រាប់ចំណាយលើសេវាចាំបាច់នានាដូចជាថ្លៃទឹក-ភ្លើង និងជួលផ្ទះ ឬបង់ថ្លៃផ្ទះ, គ្រួសារមិនទទួលសាច់ប្រាក់ឧបត្ថម្ភចំនួន ៤៣% បានរាយការណ៍ថា ធ្លាប់មិនមានលទ្ធភាពបង់ថ្លៃសេវាទាំងនេះ ខណៈដែលគ្រួសារគោលដៅចំនួន ៣០% តែប៉ុណ្ណោះ ធ្លាប់បានជួបប្រទះបញ្ហាដូចគ្នានេះ។

**រូបភាពទី៣៖ លទ្ធភាពក្នុងការចំណាយសេវាសុខាភិបាល, សេវាទឹក-ភ្លើង, ជួលផ្ទះ ផ្អែកលើទិន្នន័យជុំទី២**




*អ្នកទទួលផល “ខ” ៖ “បន្ទាប់ពីទទួលបានសាច់ប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល, ការរស់នៅរបស់គ្រួសារខ្ញុំមានភាពល្អប្រសើរជាងមុន។ ខ្ញុំបានយកប្រាក់មួយចំនួនទៅសងកម្ចី និងសេសសល់តិចតួចទិញម្ហូបអាហារ និងថ្នាំពេទ្យដើម្បីព្យាបាលជំងឺ។ ជីវភាពគ្រួសាររបស់ខ្ញុំមិនលំបាកដូចមុនពេលទទួលបានប្រាក់ឧបត្ថម្ភនោះទេ ។”*

## Health and utility expenditure

By the end of the cash transfer programmes, clear differences in the ability of households to cover their basic needs emerged. Recipient households were significantly more likely to be able to cover their medicine and medical treatment costs compared to non-recipients, as shown in Figure 3. While 61 percent of non-recipient households stated that they experienced moments where they were unable to pay for health expenditures, only 34 percent of recipient households reported any issues. Similarly, 43 percent of non-recipient households stated there were times when they could not cover the cost of basic utilities or housing (e.g., rent or mortgage costs), compared to 30 percent of recipient households.

**Figure 3: Proportion of households unable to cover costs based on second round interviews**




*Recipient B - “After I got the allowance from the government, my family is living better than before because when I receive the money, I keep some part to pay the bank loan, and the little money that I have left I keep it to buy food and medicine to treat my illness. It’s not difficult like when we didn’t get the allowance from the government.*

### ការសន្សំក្នុងគ្រួសារ និងសងកម្ចី

អត្រានៃការសន្សំក្នុងគ្រួសារគោលដៅ និងគ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភ បានធ្លាក់ចុះដូចគ្នា ចាប់តាំងពីការដាក់ឱ្យអនុវត្តកម្មវិធីទាំង ២។ កន្លងមក គ្រួសារគោលដៅប្រមាណ ២៧% បានរាយការណ៍ថា មានការសន្សំក្នុងទម្រង់ណាមួយដូចជាមាស, ប្រាក់សុទ្ធ, និងប្រាក់សន្សំនៅធនាគារ ទាបជាងគ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភដែលមានចំនួន ៣៥,៦%។ បន្ទាប់ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ត្រូវបានបិទបញ្ចប់, អត្រានៃការសន្សំក្នុងគ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភ និងគ្រួសារគោលដៅបានធ្លាក់ចុះមកត្រឹម ១៧,៨% និង ១៦,៧% រៀងគ្នា។ យ៉ាងណាមិញការធ្លាក់ចុះនៃអត្រាមានការសន្សំក្នុងគ្រួសារគោលដៅ មានកម្រិតទាបជាង។ ក្នុងន័យនេះ សាច់ប្រាក់ឧបត្ថម្ភបានជួយទប់ស្កាត់អត្រាធ្លាក់ចុះនៃការសន្សំក្នុងគ្រួសារគោលដៅចំនួន ៧,៥% ដូចក្នុងរូបភាពទី៤។

**រូបភាពទី៤៖ អត្រាមានការសន្សំក្នុងគ្រួសារ**




ជាមួយគ្នានេះ ការយឺតយ៉ាវក្នុងការសងប្រាក់កម្ចីបានថយចុះសម្រាប់ក្រុមទាំង ២ ដែលមានអត្រា ២៥% សម្រាប់គ្រួសារគោលដៅ ទាបជាងគ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភដែលមានអត្រារហូតដល់ ៣២%។ លទ្ធផលក៏បានបង្ហាញថា កម្មវិធីឧបត្ថម្ភសាច់ប្រាក់បានកាត់បន្ថយភាពយឺតយ៉ាវក្នុងការសងប្រាក់កម្ចីរបស់គ្រួសារគោលដៅចំនួន ២,៤%។ បន្ថែមលើនេះ គ្រួសារគោលដៅចំនួន ៤,៥% បានរួចផុតពីបំណុល ខ្ពស់ជាងគ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភដែលមានត្រឹម ៣,៨%។

### Household savings and loan repayment

The proportion of households with savings was shown to have decreased since the start of the cash transfer programmes. Previously, 27 percent of recipient households reported some savings, including in gold, cash, and bank accounts, which was significantly lower than the 35.6 percent of non-recipient households that reported some savings. By the end of the cash transfer programmes, only 17.8 percent of non-recipient households and 16.7 percent of recipient households reported having savings. As shown in Figure 4, although the proportion of households with savings diminished for both groups, analysis reveals that the cash transfer programmes reduced the decline of recipient households' overall savings by 7.5 percent.

**Figure 4: Household savings**




In parallel, by the end of the cash transfer programmes, late loan repayments had decreased for both groups with recipients being late (25 percent) less often than non-recipients (32 percent). The findings reveal that the cash transfer programmes have reduced late loan repayments from recipient households by 2.4 percent. Moreover, due to the cash transfers, recipient households were slightly more likely to pay off debts (4.5 percent) than non-recipients (3.8 percent).

*អ្នកទទួលផល "គ" ៖ "ខ្ញុំបានខ្ចីប្រាក់ពីគេយកទៅជួលដី និងទិញជីដើម្បីដាំឈូក។ ការដាំឈូកពុំទទួលបានទិន្នផលល្អសោះ។ ខ្ញុំមិនអាចប្រមូលផលបាន ហើយក៏ខាតប្រាក់អស់ ដែលនេះជាមូលហេតុដែលខ្ញុំគ្មានលទ្ធភាពសងប្រាក់គេ។ បន្ទាប់ពីខ្ញុំបានទទួលប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល ប្រាក់ឧបត្ថម្ភនេះបានជួយសម្រួលបន្ទុកគ្រួសាររបស់ខ្ញុំជាច្រើន។ ពេលទទួលបានប្រាក់ឧបត្ថម្ភមួយលើកៗ ខ្ញុំបានដកប្រាក់ចំនួន ១០ ០០០រៀល សងគេ ហើយសល់ចំនួន ៧០ ០០០រៀល ខ្ញុំបានចំណាយលើការសិក្សារបស់កូនៗ និងទិញម្ហូបអាហារ។ នេះជា មូលហេតុធ្វើឱ្យជីវភាពគ្រួសាររបស់ខ្ញុំប្រសើរជាងមុន។ ខ្ញុំអាចសងប្រាក់គេទាន់ពេលនិងមិនយឺតយ៉ាវដូចមុន។*

### ទស្សនៈរបស់ប្រជាពលរដ្ឋចំពោះរាជរដ្ឋាភិបាល

ជារួម ក្នុងអំឡុងពេលអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់, គ្រួសារគោលដៅ និងគ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភ មានទស្សនៈវិជ្ជមានចំពោះរាជរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់ក្រោមជាតិ ជាពិសេសពីសំណាក់គ្រួសារគោលដៅដែលមានអត្រាប្រមាណជិត ១00% ដូចបានបង្ហាញក្នុងរូបភាពទី៥។ លទ្ធផលនៃការវាយតម្លៃក៏បានបង្ហាញថា គ្រួសារគោលដៅមានទស្សនៈវិជ្ជមានចំពោះរាជរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់ក្រោមជាតិខ្ពស់ជាង ធៀបនឹងគ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភ ដែលក្នុងនោះកម្មវិធីឧបត្ថម្ភសាច់ប្រាក់បានពង្រឹងទស្សនៈវិជ្ជមានរបស់គ្រួសារគោលដៅមកលើរាជរដ្ឋាភិបាលចំនួន ៣,៥%។

**រូបភាពទី៥៖ ទស្សនៈមកលើរាជរដ្ឋាភិបាល ( ខាងលើ ) និងអាជ្ញាធរថ្នាក់ក្រោមជាតិ ( ខាងក្រោម )**




*Recipient C: "I borrowed money to rent land and buy fertilizer to grow lotus. But it didn't grow well. We couldn't harvest it, so we lost money. That's why I [didn't] have money to repay the loan. After I got the allowance from the government, it helps my family a lot. Because each time I got the money, I [kept] 10,000 KHR to pay the loan. The 70,000 KHR that was left I spent on my children's school and to buy rice, vegetables, etc. That's why my family is better off than before. I can pay the bank loan on time, not late like before."*

### Recipient perceptions of government authorities

Overall, the perceptions of recipient and non-recipient households towards national and local government remained positive for the duration of the assessment. This was especially true among recipient households, with positive perceptions reaching nearly 100 percent, as shown in Figure 5. Evaluation results revealed that recipient households held significantly higher positive perceptions of national and local government compared to non-recipient households. Furthermore, analysis suggests that the cash transfer programmes strengthened recipients' perceptions of national government by 3.5 percent.

**Figure 5: Household perceptions of national (top) and local (bottom) government between survey rounds**



### បញ្ហាប្រឈម

លទ្ធផលនៃការវាយតម្លៃ បានរំលេចនូវបញ្ហាប្រឈមចំនួន ២ ក្នុងអំឡុងពេលអនុវត្តកម្មវិធី ដូចខាងក្រោម៖

**ការយល់ដឹងអំពី កម្មវិធីឧបត្ថម្ភសាច់ប្រាក់**

ការយល់ដឹងរបស់គ្រួសារគោលដៅ និងគ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភអំពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់គ្រួសារងាយរងហានិភ័យដែលបានដាក់ចេញនាពេលកន្លងមកនៅមានកម្រិត រួមមានការយល់ដឹងអំពីនិយមន័យគ្រួសារងាយរងហានិភ័យ, ដំណើរការសម្ភាសន៍ និងការជូនដំណឹង និងជាពិសេសការយល់ដឹងច្បាស់លាស់អំពីនីតិវិធីបើកប្រាក់ឧបត្ថម្ភ និងឯកសារតម្រូវពីសំណាក់គ្រួសារគោលដៅ។

**បទពិសោធន៍នៃការបើកប្រាក់ឧបត្ថម្ភ**

គ្រួសារទទួលប្រាក់ឧបត្ថម្ភ បានលើកឡើងអំពីបញ្ហាពាក់ព័ន្ធនឹងដំណើរការបើកប្រាក់ឧបត្ថម្ភនៅតាមបញ្ជរវីងក្នុងមូលដ្ឋានរបស់ពួកគាត់ រួមមាន៖ រយៈពេលរង់ចាំ, សន្ទនិយភាពសាច់ប្រាក់របស់បញ្ជរវីង, និងការធ្វើដំណើរឆ្ងាយ និងចំណាយធ្វើដំណើរ។ ប៉ុន្តែបញ្ហាទាំងនេះត្រូវបានដោះស្រាយជាបន្តបន្ទាប់ក្នុងរយៈពេលដែលអនុវត្តកម្មវិធី។

## ៣. អនុសាសន៍គន្លឹះ

ផ្អែកលើមូលដ្ឋាននៃលទ្ធផល និងបញ្ហាប្រឈមខាងលើ, ការវាយតម្លៃនេះបានលើកជាអនុសាសន៍គន្លឹះមួយចំនួន ដើម្បីកែលម្អការរៀបចំ និងអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់នានា នាពេលអនាគត ដូចខាងក្រោម៖

១. បន្តធ្វើឱ្យប្រសើរឡើងនូវបទពិសោធបើកប្រាក់ឧបត្ថម្ភ៖ ដោយមានការលើកឡើងអំពីបញ្ហាពាក់ព័ន្ធនឹងការបើកសាច់ប្រាក់ឧបត្ថម្ភ, នីតិវិធីប្រតិបត្តិការចំពោះបញ្ជរវីងនៅមូលដ្ឋានសម្រាប់ការបើកផ្តល់ និងទូទាត់ រួមទាំងយន្តការត្រួតពិនិត្យ គួរត្រូវបានបន្តពង្រឹងបន្ថែម។ លើសពីនេះ លទ្ធភាពក្នុងការផ្តល់ជម្រើសភ្នាក់ងារបើកផ្តល់បន្ថែមទៀតក៏គួរត្រូវបានគិតគូរដើម្បីអនុញ្ញាតឱ្យអ្នកទទួលផលអាចទៅបើកប្រាក់ឧបត្ថម្ភ នៅតាមបញ្ជរភ្នាក់ងារបើកផ្តល់ ឬធនាគារណាមួយដែលពួកគាត់ជ្រើសរើស ដែលនេះជាផ្នែកមួយក្នុងការអនុវត្តគោលនយោបាយបរិយាបន្នហិរញ្ញវត្ថុ។

២. ពិនិត្យ និងវាយតម្លៃអំពីភាពគ្រប់គ្រាន់នៃប្រាក់ឧបត្ថម្ភ៖ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដែលបានដាក់ចេញ បានសម្រេចគោលដៅក្នុងការជួយសម្រាលបន្ទុកជីវភាពរបស់គ្រួសារគោលដៅពីផលប៉ះពាល់ធ្ងន់ធ្ងរនៃសម្ពាធអតិផរណា និងទឹកជំនន់។ ទោះជាយ៉ាងនេះក្តី ការពិនិត្យ និងវាយតម្លៃអំពីទំហំ និងភាពគ្រប់គ្រាន់

### Challenges

The evaluation results revealed two key challenges experienced during implementation of the cash transfer programmes, as follows.

**Limited awareness of the cash transfer programmes among at-risk households**

Both recipient and non-recipient households showed limited awareness of the cash transfer programmes. This included limited awareness of the definition of at-risk households, interview and notification processes, and, in particular, cash withdrawal procedures and requirements among recipient households.

**Issues with the cash receipt experience**

Recipient households reported issues related to the withdrawal of their cash transfers at local WING branches, including long wait times to withdraw cash, liquidity issues among WING agents, long travel distances, and associated costs. However, these issues have been addressed continuously during the programme implementation.

## III. KEY RECOMMENDATIONS

Taking these findings into consideration, the following recommendations are made to improve future implementations of cash transfer programmes:

1. Further improve the cash withdrawal experience: As recipient households reported some issues related to cash withdrawal, conducting a stricter operations procedure for the local payment branches in disbursement and reconciliation of cash transfers and corresponding oversight mechanisms is recommended. In addition, it is recommended to explore the possibility of providing multiple options for cash transfer recipients, in which eligible recipients can cash out at their preferred cash agents or banks as part of a financial inclusion policy.

2. Assess cash transfer adequacy: The cash transfer programmes served their objective,

នៃសាច់ប្រាក់ឧបត្ថម្ភ ជាប្រចាំក្នុងអំឡុងពេលអនុវត្តកម្មវិធី មានសារៈសំខាន់ ដើម្បីទប់ស្កាត់គ្រួសារប្រជាពលរដ្ឋមិនឱ្យធ្លាក់ចូលទៅក្នុងភាពក្រីក្រ ជាពិសេសក្នុងបរិបទនៃការបន្តកើនឡើងនៃថ្លៃទំនិញ។

៣. បង្កើនការផ្សព្វផ្សាយដល់អ្នកទទួលផល និងមន្ត្រីអនុវត្តកម្មវិធីនៅមូលដ្ឋាន៖ ការយល់ដឹងរបស់គ្រួសារគោលដៅ និងគ្រួសារមិនទទួលបានប្រាក់ឧបត្ថម្ភអំពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់នៅមានកម្រិត ដែលទាមទារឱ្យមានការជំរុញ និងលើកកម្ពស់ជាចាំបាច់។ គ្រោះអាសន្នពីផលប៉ះពាល់នៃសម្ពាធអតិផរណា និងទឹកជំនន់ទាមទារឱ្យមានវិធានការឆ្លើយតបឱ្យបានទាន់ពេល។ ក្នុងន័យនេះ យុទ្ធនាការផ្សព្វផ្សាយ និងបង្កើនការយល់ដឹងអំពីនីតិវិធីអនុវត្តកម្មវិធី, លក្ខខណ្ឌក្នុងការទទួលផល និងអត្ថប្រយោជន៍ គឺមានភាពចាំបាច់ដើម្បីបញ្ជ្រាបការយល់ដឹងជូនដល់អ្នកទទួលផល, សហគមន៍មូលដ្ឋាន, និងមន្ត្រីអនុវត្តកម្មវិធីនៅមូលដ្ឋាន ។

៤. រៀបចំ និងត្រៀមទុកជាមុននូវកម្មវិធីគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន៖ ដើម្បីធានាបាននូវការឆ្លើយតបដែលមានលក្ខណៈជាប្រព័ន្ធ និងទាន់ពេល ស្របទៅនឹងការអាចកើតមានជាញឹកញាប់នៃសម្ពាធអតិផរណា និងគ្រោះទឹកជំនន់, ការរៀបចំ និងត្រៀមទុកជាមុននូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដើម្បីឆ្លើយតបនឹងគ្រោះអាសន្នទាំងនេះគួរត្រូវបានគិតគូរ រួមទាំងការកំណត់ឱ្យបានច្បាស់អំពីកម្រិតធ្ងន់ធ្ងរនៃសម្ពាធអតិផរណា និងប្រភេទនៃភាពងាយរងគ្រោះ ដែលទាំងនេះអាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការដាក់ចេញនូវអន្តរាគមន៍គាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្នដែលសមស្រប។ ការអនុវត្តនូវអនុសាសន៍នេះ គឺអនុលោមតាម “គោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន” ដែលរាជរដ្ឋាភិបាលទើបបានអនុម័ត នាពេលថ្មីៗនេះ។

៥. បន្តគាំទ្រដល់គ្រួសារងាយរងហានិភ័យ៖ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដែលបានដាក់ចេញបានជួយសម្រួលបន្ទុកជីវភាព និងកាត់បន្ថយសម្ពាធហិរញ្ញវត្ថុរបស់គ្រួសារងាយរងហានិភ័យ។ យ៉ាងណាមិញ ឥទ្ធិពលជាវិជ្ជមាននៃកម្មវិធីទាំងនេះ មានភាពថមថយស្របពេលដែលកម្មវិធីឧបត្ថម្ភសាច់ប្រាក់ទាំងនេះត្រូវបានបិទបញ្ចប់។ ក្នុងន័យនេះ ការដាក់ចេញនូវកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស និងការពង្រីកវិសាលភាពមូលនិធិសមធម៌សុខាភិបាល គឺជាការបន្តគាំទ្រផ្នែកជំនួយសង្គមដ៏សំខាន់ដល់ក្រុមគោលដៅនេះ បន្ថែមទៀត។







រូបភាព៖ GS-NSPC





រូបភាព៖ GS-NSPC



រូបភាព៖ Department of Poor Household Identification, Ministry of Planning

which was to ease the impacts of rising inflation and the effects of severe floods on people's livelihoods. Nevertheless, conducting reviews on the adequacy of the cash transfer benefits periodically during programme implementation is recommended to effectively prevent people from falling into poverty, particularly in the context of rising prices.

3. Enhance outreach to potential recipients and local implementers: Limited awareness of the cash transfer programmes among both recipient and non-recipient households should be addressed. While the emergencies of rising inflation and severe floods needed to trigger urgent programmatic responses, greater outreach and communication campaigns should be provided to better inform potential beneficiaries, grassroots communities, and local implementers on the programme implementation procedure, eligibility criteria, and benefits.

4. Plan for ex-ante shock-responsive social protection programmes: Considering the frequent and recurrent nature of inflation and floods in addition to their impacts, systematic and timely responses are needed. It is therefore recommended to conduct ex-ante planning of cash transfer programmes. This includes clearly defining the threshold of inflationary pressure and types of vulnerabilities that could trigger an appropriate shock-responsive social protection intervention. This is in line with the newly adopted Guideline on the Shock-Responsive Social Protection Framework.

5. Ensure continued support to at-risk households: While the cash transfer programmes helped to support the livelihoods of at-risk households and their management of increasing financial pressure, this progress is threatened as the programmes have come to completion. Therefore, the launching of the technical and vocational education training programme and the extension of Health Equity Fund benefits are the continued social assistance supports, which are critical important to this target group.